អង្គការសហប្រជាជាតិ A/RES/56/169

មហាសន្និបាត

ការចែកចាយទូទៅ

ថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០០២

សម័យប្រជុំលើកទី ៥៦

ចំណុចរបៀបវារៈទី ១១៩ (ខ)

# សេចក្តីសម្រេចចិត្តអនុម័តដោយមហាសន្និបាត

(លើរបាយការណ៍របស់គណៈកម្មាធិការទី ៣ *(A/56/583/Add.2)*)

## ៥៦/១៦៩. ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

មហាសន្និបាត

ណែនាំដោយទិសដៅ និងគោលការណ៍ ដែលមានចែងនៅក្នុងធម្មនុញ្ញសហប្រជាជាតិ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស[១] និងអនុសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស[២]

រំលឹកឡើងវិញ កិច្ចព្រមព្រៀងស្តីពីការដោះស្រាយតាមផ្លូវនយោបាយដោយសព្វមុខ នៃជម្លោះកម្ពុជា ចុះហត្ថលេខានៅទីក្រុងប៉ារីស នាថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១[៣] ដែលក្នុងនោះរួមមានផ្នែកទី ៣ ទាក់ទិនទៅនឹងបញ្ហាសិទ្ធិមនុស្ស

[១] សេចក្តីសម្រេចចិត្តលេខ 217 A (III)

[២] សេចក្តីសម្រេចចិត្តលេខ 2200 A (XXI) ឧបសម្ព័ន្ធ

[៣] A/46/608-S/23177

រំលឹកឡើងវិញផងដែរសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ ៥៥/៩៥ ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០០ និងសេចក្តីសំរេចចិត្តរបស់របស់គណៈកម្មការសិទ្ធិមនុស្ស លេខ ២០០១/៨២ ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០០១[៤] និងសេចក្តីសំរេចចិត្តមានពាក់ព័ន្ធលើកមុនៗ

ទទួលស្គាល់ថាប្រវត្តិសាស្ត្រប្រកបដោយសោកនាដកម្មនៃប្រទេសកម្ពុជា ទាមទារនូវវិធានការពិសេស ដើម្បីធានាការការពារសិទ្ធិមនុស្សនៃជនទាំងអស់រស់នៅក្នុងប្រទេសកម្ពុជា និងការមិនត្រឡប់មកវិញនូវនយោបាយ និងការអនុវត្តន៍នៃអតីតកាល ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងចុះហត្ថលេខានៅទីក្រុងប៉ារីស៍នៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១

ប្រាថ្នាចង់ឱ្យសហគមន៍អន្តរជាតិបន្តឆ្លើយតបជាវិជ្ជមាន ដើម្បីជួយដល់កិច្ចខិតខំទាំងឡាយ ដើម្បីធ្វើការស៊ើបអង្កេតទៅលើប្រវត្តិសាស្ត្រប្រកបដោយសោកនាដកម្មនៃប្រទេសកម្ពុជា ក្នុងនេះរួមមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មជាអន្តរជាតិពីអតីតកាល ដូចជាការសម្លាប់រង្គាល និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងរយៈពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ជាដើម

ចងចាំជានិច្ចនៅក្នុងអារម្មណ៍ សេចក្តីស្នើសុំជំនួយកាលពីខែមិថុនា ឆ្នាំ ១៩៩៧ របស់អាជ្ញាធរកម្ពុជា ដើម្បីឆ្លើយតបទៅនឹងការរំលោភដ៏ធ្ងន់ធ្ងរកាលពីអតីតកាល ទៅលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ លិខិតចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ១៩៩៩ របស់លោកអគ្គលេខាធិការជូនចំពោះប្រធានមហាសន្និបាត និងប្រធានក្រុមប្រឹក្សាសន្តិសុខ[៥] និងរបាយការណ៍របស់ក្រុមអ្នកជំនាញការតែងតាំងឡើងដោយលោកអគ្គលេខាធិការ ដែលភ្ជាប់មកជាឧបសម្ព័ន្ធនៅក្នុងនេះ និងកិច្ច ពិភាក្សារវាងរដ្ឋាភិបាលកម្ពុជា និងលេខាធិការដ្ឋានអង្គការសហប្រជាជាតិ ស្តីពីបទដ្ឋាន និងនីតិវិធីសំរាប់នាំខ្លួនពួកមេដឹកនាំខ្មែរក្រហមដែលទទួលខុសត្រូវជាងគេបំផុត ចំពោះការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុត ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទៅកាន់តុលាការ

ទទួលស្គាល់ការព្រួយបារម្ភដ៏ត្រឹមត្រូវ របស់រដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការស្វែងរកគោលការណ៍ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៃភាពយុត្តិធម៌ និងការបង្រួបបង្រួមជាតិ

ទទួលស្គាល់ផងដែរថាការទទួលខុសត្រូវជាបុគ្គល របស់អ្នកប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ គឺជាចំណុចសំខាន់មួយនៃកត្តាផ្សេងៗ នៃការព្យាបាលប្រកបដោយប្រសិទ្ធភាព សំរាប់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស និង

---

[៤] សូមមើលកំណត់ជាផ្លូវការរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ឆ្នាំ ២០០១ សេចក្តីបន្ថែមលេខ ៣ (E/2001/23) ជំពូក ២ ផ្នែក ក

[៥] A/53/850-S/1999/231

ជាកត្តាជាគន្លឹះមួយក្នុងការធានាឱ្យមានប្រព័ន្ធយុត្តិធម៌មួយត្រឹមត្រូវ និងប្រកបដោយសមធម៌ ហើយទីបំផុតឱ្យមានការបង្រួបបង្រួម និងស្ថេរភាពនៅក្នុងរដ្ឋមួយ

ស្វាគមន៍ការបន្តតួនាទីរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការលើកតម្កើង និងការការពារសិទ្ធិមនុស្ស នៅក្នុងប្រទេសកម្ពុជា

I- ការគាំទ្រ និងកិច្ចសហប្រតិបត្តិការ ជាមួយអង្គការសហប្រជាជាតិ

១- ស្នើសុំលោកអគ្គលេខាធិការ តាមរយៈតំណាងពិសេសទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជារបស់លោក សហការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ជួយដល់រដ្ឋាភិបាលកម្ពុជាក្នុងការធានាការការពារសិទ្ធិមនុស្សរបស់ជនទាំងអស់រស់នៅក្នុងប្រទេសកម្ពុជា និងធានាឱ្យមានធនធានគ្រប់គ្រាន់សំរាប់កិច្ចដំណើរការជាបន្តនៃវត្តមានប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា នៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា និងដើម្បីឱ្យលោកតំណាងពិសេសអាចបន្តបំពេញកិច្ចការរបស់លោកប្រកបដោយប្រសិទ្ធភាព ។

២- ស្វាគមន៍របាយការណ៍របស់លោកអគ្គលេខាធិការ ស្តីពីតួនាទី និងលទ្ធផលសំរេចបាន របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយដល់រដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកតម្កើង និងការការពារសិទ្ធិមនុស្ស[៦] ។

៣- ស្វាគមន៍ផងដែររបាយការណ៍របស់លោកតំណាងពិសេស[៧] សរសើរដល់រដ្ឋាភិបាលកម្ពុជា ក្នុងការបើកចំហ និងស្មារតីសហប្រតិបត្តិការ ក្នុងពេលបំពេញទស្សនកិច្ចរបស់លោកតំណាងពិសេស លើកទឹកចិត្តដល់រដ្ឋាភិបាលសូមឱ្យបន្តកិច្ចសហប្រតិបត្តិការរបស់ខ្លួននៅគ្រប់ជាន់ថ្នាក់ទាំងអស់នៃរដ្ឋាភិបាល គាំទ្រសេចក្តីអំពាវនាវរបស់រដ្ឋាភិបាលកម្ពុជា និងលោកតំណាងពិសេស សុំឱ្យបង្កើនជំនួយអន្តរជាតិដល់រដ្ឋាភិបាលកម្ពុជា និងបន្តធ្វើការឆ្ពោះទៅកាត់បន្ថយភាពក្រីក្រ សរសើរដល់សហគមន៍អន្តរជាតិចំពោះការយកចិត្តទុកដាក់ និងការគាំទ្រ ដែលបានសំដែងឱ្យឃើញនៅក្នុងកិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់ស្តីពីកម្ពុជា ដែលបានប្រព្រឹត្តទៅនៅទីក្រុងតូក្យូ នៅថ្ងៃទី ១២ និង ១៣ ខែមិថុនា ឆ្នាំ ២០០១

[៦] A/56/230

[៧] សូមមើល A/56/209

កន្លងទៅនេះ និងលើកទឹកចិត្តដល់ប្រទេសផ្តល់ជំនួយ និងភាគីមានពាក់ព័ន្ធដទៃទៀត សូមតាមដានកិច្ចសន្យាផ្តល់ជំនួយ និងការជាប់ពាក់ព័ន្ធរបស់ខ្លួន ។

៤- សុំរដ្ឋាភិបាលកម្ពុជា បន្តសហប្រតិបត្តិការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដើម្បីដោះស្រាយបញ្ហាសំខាន់ ៗ ស្របទៅតាមបទដ្ឋានអន្តរជាតិ ដោយពុំពន្យារពេលថែមទៀត ដើម្បីភាគីទាំងពីរអាចចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចព្រមព្រៀង ដើម្បីបន្តអាណត្តិរបស់ការិយាល័យឧត្តមស្នងការនៅក្នុងប្រទេសកម្ពុជា កត់សំគាល់ដោយសោកស្តាយ នូវការពន្យារពេលនៃកិច្ចដំណើរការនេះរហូតមកដល់ពេលនេះ និងលើកទឹកចិត្តរដ្ឋាភិបាលកម្ពុជាសូមឱ្យបន្តកិច្ចសហប្រតិបត្តិការជាមួយការិយាល័យជាបន្តទៅទៀត ។

៥- កត់សំគាល់ដោយពេញចិត្ត ការប្រើប្រាស់មូលនិធិនៃការរួមវិភាគទានដោយស្ម័គ្រចិត្តដោយលោកអគ្គលេខាធិការ សំរាប់កម្មវិធីអប់រំសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ដើម្បីផ្តល់ជាថវិការដល់កម្មវិធីសកម្មភាពរបស់ការិយាល័យឧត្តមស្នងការប្រចាំកម្ពុជា ដូចដែលបានកំណត់នៅក្នុងសេចក្តីសំរេចចិត្តនានារបស់មហាសន្និបាត និងរបស់គណៈកម្មការសិទ្ធិមនុស្ស ហើយសូមរដ្ឋាភិបាល អង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល មូលនិធិ និងបុគ្គលនានាពិនិត្យពិចារណា ក្នុងការចូលរួមវិភាគទានដល់មូលនិធិនៃការរួមវិភាគទានដោយស្ម័គ្រចិត្តនេះផង ។

## II- ការកែទម្រង់ រដ្ឋបាល នីតិកម្ម និងប្រព័ន្ធតុលាការ

១- កត់សំគាល់ដោយយកចិត្តទុកដាក់ ការបន្តកើតមាននូវបញ្ហាទាក់ទិនទៅនឹងនីតិរដ្ឋ និងការប្រព្រឹត្តទៅរបស់តុលាការ បណ្តាលមកពី ក្នុងចំណោមបញ្ហាផ្សេង ៗ អំពើពុករលួយ ក្នុងនេះរួមមានការជ្រៀតជ្រែកពីអំណាចនីតិប្រតិបត្តិទៅលើឯករាជ្យភាពរបស់តុលាការ ស្វាគមន៍ការបន្តការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការកែទម្រង់ប្រព័ន្ធតុលាការ និងអំពាវនាវដល់រដ្ឋាភិបាល សូមបន្តចាត់វិធានការចាំបាច់ទាំងឡាយ ដើម្បីជំរុញឯករាជ្យភាព ភាពមិនលំអៀង និងប្រសិទ្ធភាព របស់ក្រុមប្រឹក្សានៃអង្គចៅក្រម និងប្រព័ន្ធយុត្តិធម៌ទាំងមូល និងដើម្បីបង្កើនថវិការដល់ប្រព័ន្ធតុលាការ ក្នុងក្តីសង្ឃឹមថានឹងអាចកាត់បន្ថយចំនួននៃការឃុំខ្លួនមុនកាត់ក្តីហួសកំណត់ ។

២- អំពាវនាវដល់រដ្ឋាភិបាលកម្ពុជា សូមបន្តការខិតខំរបស់ខ្លួនឆ្ពោះទៅការអនុម័តឱ្យបានឆាប់ច្បាប់ និងក្រិត្យនានាដែលជាសមាសភាគសំខាន់នៃគ្រោងច្បាប់ជាមូលដ្ឋាន ក្នុងនេះរួមមានពង្រាងលក្ខន្តិកៈចៅក្រម ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណីថ្មី និងក្រមនីតិវិធីរដ្ឋប្បវេណី ក៏ដូចជាការខិតខំរបស់ខ្លួនដើម្បីកែទម្រង់ការគ្រប់

ត្រង់ផ្នែកយុត្តិធម៌ និងបង្កើនការហ្វឹកហ្វឺនចៅក្រម និងមេធាវី  អំពាវនាវដល់សហគមន៍អន្តរជាតិសូមឱ្យជួយរដ្ឋាភិបាលក្នុងទិសដៅនេះ និងស្វាគមន៍ចំពោះពង្រាងច្បាប់ស្តីពីរុក្ខា និងជលផល ។

៣- ស្វាគមន៍ការអនុម័តច្បាប់ភូមិបាល គត់សំគាល់ដោយសេចក្តីព្រួយបារម្ភបញ្ហាទាក់ទិននឹងរឿងដីធ្លី ក្នុងនេះមានការរឹបអូសយកដី ការបណ្តេញដោយបង្ខំ និងការផ្លាស់ប្តូរទីកន្លែងបន្ថែម និងអំពាវនាវដល់រដ្ឋាភិបាលសូមបន្តការខិតខំរបស់ខ្លួនដើម្បីអនុវត្តន៍ប្រព័ន្ធចុះបញ្ជីដីធ្លី ប្រកបដោយប្រសិទ្ធភាព ពិតប្រាកដ និងតម្លាភាព ដូចដែលបានកំណត់នៅក្នុងច្បាប់ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ។

៤-  ស្វាគមន៍ផងដែរ  កិច្ចខិតខំរបស់រដ្ឋាភិបាលកម្ពុជាដើម្បីអនុវត្តន៍កម្មវិធីកែទម្រង់របស់ខ្លួន  រួមមានការអនុម័តផែនការសកម្មភាពខាងអភិបាលកិច្ច  លើកទឹកចិត្តដល់ការអនុវត្តន៍តាមកាលកំណត់ និងដោយប្រសិទ្ធភាព ផែនការនេះ និងអំពាវនាវដល់សហគមន៍អន្តរជាតិឱ្យជួយរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចខិតខំរបស់ខ្លួន ឆ្ពោះទៅទិសដៅនេះ ។

៥-  សំដែងសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង  ដោយស្ថានភាពនិទ្ទណ្ឌភាពនៅតែស្ថិតមាននៅឡើយនៅក្នុងប្រទេសកម្ពុជា  ទទួលស្គាល់ការប្តូរផ្តាច់ និងការខិតខំរបស់រដ្ឋាភិបាលកម្ពុជា ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ អំពាវនាវដល់រដ្ឋាភិបាល  ដោយចាត់ទុកបញ្ហានេះជាបញ្ហាមួយនៃអាទិភាពជាចំបង  សូមឱ្យចាត់វិធានការបន្ថែមទៀតដើម្បីធ្វើការស៊ើបអង្កេតជាបន្ទាន់ និងផ្តន្ទាទោស ស្របទៅតាមកិច្ចដំណើរការត្រឹមត្រូវនៃច្បាប់  និងបទដ្ឋានអន្តរជាតិ  ចំពោះមនុស្សទាំងអស់ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ  រួមទាំងការរំលោភសិទ្ធិមនុស្សផង  និងអំពាវនាវដល់សហគមន៍អន្តរជាតិសូមជួយផ្តល់មធ្យោបាយនានា ដូចជាជំនួយបច្ចេកទេស  ឬជំនាញការ  ដើម្បីជួយរដ្ឋាភិបាលឱ្យសំរេចបាននូវការប្តូរផ្តាច់របស់ខ្លួន ដើម្បីនាំខ្លួនជនល្មើសទៅកាន់តុលាការឱ្យបានប្រសិទ្ធភាពជាងនេះ ។

៦-  ស្វាគមន៍កិច្ចខិតខំរបស់រដ្ឋាភិបាលកម្ពុជា  ក្នុងការរំសាយកងកម្លាំងប្រដាប់អាវុធ  រួមមានការចាប់ផ្តើមកម្មវិធីកាត់រំសាយកងទ័ពចំណែកទី ១  លើកទឹកចិត្តរដ្ឋាភិបាលឱ្យអនុវត្តន៍ខ្លឹមសារនៃសៀវភៅសស្តីពីការការពារជាតិ និងបន្តការកែទម្រង់ដោយប្រសិទ្ធភាព  រួមមានការអនុវត្តន៍កម្មវិធីកាត់រំសាយកងទ័ពដោយទ្រង់ទ្រាយចំពេញបន្ទុក  ដែលបញ្ចូលទាំងការដកអាវុធពីទាហានដែលបានត្រូវកាត់រំសាយផង  ដោយឈរលើបទពិសោធន៍បានមកពីគំរោងការជាគំរូ  ក្នុងទិសដៅឆ្ពោះទៅបង្កើតកងកម្លាំងនគរបាល  និងយោធាអាជីព  និងមិនលំអៀង  និងសុំឱ្យសហគមន៍អន្តរជាតិបន្តជួយរដ្ឋាភិបាលសំរេចទិសដៅនេះ ។

៧- ស្វាគមន៍ផងដែរការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ និងច្បាប់បោះឆ្នោតស្តីពីការជ្រើសរើសទីប្រឹក្សាឃុំ/សង្កាត់ និងការបោះឆ្នោតដែលគ្រោងនឹងធ្វើនៅថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០០២ ខាងមុខនេះ អំពាវនាវយ៉ាងខ្លាំងដល់រដ្ឋាភិបាលកម្ពុជា រួមទាំងនៅថ្នាក់មូលដ្ឋាន និងខេត្តផង សូមឱ្យដឹកនាំការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ដោយពុំមានអំពើហិង្សាទៅលើគណបក្សណាមួយ ហើយសូមជំរុញដល់សហគមន៍អន្តរជាតិសូមជួយរដ្ឋាភិបាលក្នុងទិសដៅនេះ អំពាវនាវយ៉ាងខ្លាំងផងដែរដល់គណបក្សនយោបាយទាំងអស់សូមឱ្យចូលរួមការបោះឆ្នោតដោយវិធីប្រជាធិបតេយ្យ និងសន្តិភាព ហើយ ក្នុងន័យនេះ សូមស្វាគមន៍ដល់កិច្ចព្រមព្រៀងរវាងគណបក្សកាន់អំណាចទាំងពីរ ដែលថាជៀសវាងអំពើហិង្សា អំពាវនាវដល់រដ្ឋាភិបាលកម្ពុជា សូមធ្វើការស៊ើបអង្កេតដោយហ្មត់ចត់ទៅលើករណីនៃអំពើហិង្សានិងការបំភិតបំភ័យដែលកើតមានឡើង និងគូសបញ្ជាក់អំពីសារសំខាន់នៃឯករាជ្យភាព និងតម្លាភាព របស់គណៈកម្មាធិការជាតិ ខេត្ត និងឃុំរៀបចំការ បោះឆ្នោត ។

៨- កត់សំគាល់ដោយសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង អំពីលក្ខណៈពន្ធនាគារនៅក្នុងប្រទេសកម្ពុជា កត់សំគាល់ដោយយកចិត្តទុកដាក់ការខិតខំសំខាន់ ៗ ខ្លះ ដើម្បីកែលំអប្រព័ន្ធពន្ធនាគារ ស្នើសុំបន្តជំនួយអន្តរជាតិដើម្បីកែលំអលក្ខណៈខាងសម្ភារៈនៃការឃុំឃាំង និងអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា សូមឱ្យចាត់វិធានការបន្ថែមទៀតដើម្បីកែលំអលក្ខណៈនៃការឃុំឃាំង ផ្តល់ការថែរក្សាសុខភាពត្រឹមត្រូវដល់អ្នកជាប់ឃុំ រួមមានការពង្រឹងការសំរបសំរួលតួនាទីរបស់នាយកដ្ឋានសុខភាពរបស់ពន្ធនាគារ ជាមួយក្រសួងសុខាភិបាល អាជ្ញាធរខេត្ត និងអង្គការក្រៅរដ្ឋាភិបាលធ្វើការក្នុងវិស័យនេះ និងបង្ការយ៉ាងណាកុំឱ្យមានទារុណកម្ម ។

## III- ការរំលោភសិទ្ធិមនុស្ស និងអំពើហិង្សា

១- សំដែងសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង ចំពោះការបន្តការកើតមានការរំលោភសិទ្ធិមនុស្ស រួមមានទារុណកម្មការឃុំខ្លួនមុនកាត់ក្តីហួសកំណត់ ការរំលោភសិទ្ធិការងារ និងការបណ្តេញដោយបង្ខំ ក៏ដូចជាហិង្សានយោបាយ ការជាប់ពាក់ព័ន្ធរបស់នគរបាលក្នុងអំពើហិង្សា និងការខ្វះការការពារកុំឱ្យមានការសម្លាប់ដោយហ្វូងមហាជន ដូចបានរៀបរាប់នៅក្នុងរបាយការណ៍របស់លោកតំណាងពិសេស កត់សំគាល់ការរីកចំរើនខ្លះដែលរដ្ឋាភិបាលបានធ្វើដើម្បីដោះស្រាយបញ្ហាទាំងនេះ និងអំពាវនាវដល់រដ្ឋាភិបាលសូមឱ្យចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីទប់ស្កាត់ការរំលោភទាំងនេះ ។

២- អំពាវនាវសូមឱ្យបញ្ចប់អំពើហិង្សាខាងពូជសាសន៍ និងការនិយាយអាក្រក់ ប្រឆាំងទៅលើជនជាតិភាគតិច និងអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាសូមចាត់គ្រប់វិធានការទាំងអស់ ដើម្បីទប់ស្កាត់អំពើហិង្សាបែបនេះ ក៏ដូចជាដើម្បី

បំពេញកាតព្វកិច្ចរបស់ខ្លួន ដែលជាភាគីមួយនៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់គ្រប់រូបភាពនៃការរើសអើងពូជសាសន៍[៨] ក្នុងនេះមានការស្វែងរកជំនួយបច្ចេកទេសផង ។

## IV- តុលាការខ្មែរក្រហម

១- បញ្ជាក់ជាថ្មីថា ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុតនៅក្នុងប្រទេសកម្ពុជា នៅក្នុងប្រវត្តិសាស្ត្រនាពេលថ្មីៗ កន្លងទៅនេះ ត្រូវបានប្រព្រឹត្តឡើងដោយពួកខ្មែរក្រហម និងទទួលស្គាល់ថាការរលំដួលជាចុងក្រោយនៃខ្មែរក្រហម និងការខិតខំជាបន្តរបស់រដ្ឋាភិបាលកម្ពុជា បានបើកផ្លូវឆ្ពោះទៅកាន់ការរៀបចំឡើងវិញនូវសន្តិភាព ស្ថេរភាព និងការបង្រួបបង្រួមជាតិនៅក្នុងប្រទេសកម្ពុជា និងការស៊ើបអង្កេត និងការផ្តន្ទាទោស ពួកមេដឹកនាំខ្មែរក្រហម ។

២- ស្វាគមន៍ការប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតសាលាជំនុំជំរះវិសាមញ្ញនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ដើម្បីធ្វើការកាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ កត់សំគាល់ដោយពេញចិត្តបទបញ្ញត្តិ និងសមត្ថភាពទូទៅរបស់ច្បាប់ និងបទបញ្ញត្តិរបស់ច្បាប់ស្តីពីតួនាទីរបស់អង្គការសហប្រជាជាតិ អំពាវនាវដល់រដ្ឋាភិបាលកម្ពុជា សូមឱ្យធានាថាពួកមេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និងពួកអ្នកដែលទទួលខុសត្រូវជាងគេបំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភដ៏ធ្ងន់ធ្ងរលើច្បាប់ព្រហ្មទ័ណ្ឌកម្ពុជា ច្បាប់និងទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ និងអនុសញ្ញាអន្តរជាតិនានាដែលទទួលស្គាល់ដោយប្រទេសកម្ពុជា ត្រូវនាំខ្លួនទៅកាន់ការកាត់ទោសស្របតាមបទដ្ឋានអន្តរជាតិ នៃភាពយុត្តិធម៌ ភាពត្រឹមត្រូវ និងកិច្ចដំណើរការត្រឹមត្រូវតាមផ្លូវច្បាប់ ជំរុញរដ្ឋាភិបាលសូមបន្តសហការជាមួយអង្គការសហប្រជាជាតិតទៅទៀតក្នុងបញ្ហានេះ ស្វាគមន៍កិច្ចខិតខំរបស់លេខាធិការដ្ឋានអង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ ក្នុងការជួយរដ្ឋាភិបាលដើម្បីសំរេចទិសដៅនេះ អំពាវនាវដល់រដ្ឋាភិបាល និងអង្គការសហប្រជាជាតិ សូមឱ្យសំរេចឡើងនូវកិច្ចព្រមព្រៀងមួយដោយមិនបន្ថយពេលតទៅទៀត ដើម្បីឱ្យសាលាជំនុំជំរះវិសាមញ្ញ អាចចាប់ផ្តើមដំណើរការបានយ៉ាងឆាប់ និងអំពាវនាវដល់សហគមន៍អន្តរជាតិសូមផ្តល់ជំនួយក្នុងបញ្ហានេះ រួមមានការគាំទ្រជាហិរញ្ញវត្ថុ និងបុគ្គលិក ដល់សាលាជំនុំជំរះក្តីនេះ ។

## V- ការការពារស្ត្រី និងកុមារ

១- ស្វាគមន៍ចំពោះការរីកចំរើនក្នុងការកែលំអឋានៈរបស់ស្ត្រី និងអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាសូមធានាឱ្យមានការសមស្រប ដើម្បីលុបបំបាត់គ្រប់រូបភាពនៃការរើសអើងប្រឆាំងនារីភេទ ប្រយុទ្ធប្រឆាំងអំពើហិង្សាប្រឆាំងនារី

[៨] សេចក្តីសំរេចចិត្តលេខ 2106 A (XXI) ឧបសម្ព័ន្ធ

ភេទតាមគ្រប់រូបភាព និងចាត់វិធានការទាំងអស់ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន ជាភាគីមួយនៃអនុសញ្ញាស្តីពីការលុបបំបាត់គ្រប់រូបភាពនៃការរើសអើងប្រឆាំងនារីភេទ[៥] ក្នុងនេះមានការស្វែងរកជំនួយបច្ចេកទេសផង ។

២- កត់សំគាល់ដោយសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង នូវបាតុភូតដែលនៅតែមានជាបន្ត និងកាន់តែរីកដុះដាលឡើង នូវការជួញដូរ និងអាជីវកម្មផ្លូវភេទ លើស្ត្រី និងកុមារ និងការកើនឡើងនៃការកើតមាននូវ HIV/AIDS ហើយសុំឱ្យរដ្ឋាភិបាលកម្ពុជា ដោះស្រាយបញ្ហាទាំងនេះ និងមូលហេតុឫសគល់របស់វាដោយសព្វមុខ ។

៣- អំពាវនាវដល់រដ្ឋាភិបាលកម្ពុជា សូមកែលំអថែមទៀតនូវលក្ខណៈសុខភាពរបស់កុមារ និងការទទួលបានការអប់រំរបស់ពួកគេ ផ្តល់ និងជំរុញឱ្យទទួលបានការចុះសំបុត្រកំណើតដោយសេរី និងបង្កើតប្រព័ន្ធតុលាការសំរាប់ក្មេងដែលសមស្របទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងសូមសហគមន៍អន្តរជាតិបន្តជួយរដ្ឋាភិបាលដើម្បីសំរេចទិសដៅនេះ ។

៤- កត់សំគាល់ដោយសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង បញ្ហាការងារកុមារក្នុងរូបភាពដ៏សែនអាក្រក់អាក្រីបំផុត អំពាវនាវដល់រដ្ឋាភិបាលកម្ពុជា សូមឱ្យចាត់វិធានការជាបន្ទាន់ និងប្រកបដោយប្រសិទ្ធភាព ដើម្បីការពារកុមារឱ្យរួចផុតពីការធ្វើអាជីវកម្មខាងសេដ្ឋកិច្ច និងការធ្វើការងារដែលអាចមានគ្រោះថ្នាក់ ប៉ះពាល់ដល់ការរៀនសូត្ររបស់ពួកគេ ឬនាំឱ្យខូចដល់សុខភាព សុវត្ថិភាព ឬផ្លូវចិត្តរបស់ពួកគេ ដោយជំរុញឱ្យអនុវត្តន៍ច្បាប់ស្តីពីការងារកុមារកម្ពុជា ច្បាប់ការងារដែលមានស្រាប់ និងបទបញ្ញត្តិនៃច្បាប់ប្រឆាំងការជួញដូរមនុស្សទាក់ទិនទៅនឹងកុមារ និងផ្តន្ទាទោសពួកអ្នករំលោភច្បាប់ទាំងនេះ សូមស្នើដល់អង្គការការងារអន្តរជាតិបន្តពង្រីកជំនួយជាចាំបាច់ក្នុងទិសដៅនេះ និងជំរុញដល់រដ្ឋាភិបាលកម្ពុជា សូមពិនិត្យផ្តល់សច្ចាប័ណ្ណដល់អនុសញ្ញាការងារអន្តរជាតិ ស្តីពីការហាមឃាត់ និងវិធានការជាបន្ទាន់ ដើម្បីលុបបំបាត់រូបភាពដ៏អាក្រក់អាក្រីបំផុតនៃការងារកុមារ អនុសញ្ញាលេខ ១៨២ អនុម័តនៅឆ្នាំ ១៩៩៩ ។

## VI- ការធ្វើឱ្យប្រសើរឡើងនូវសិទ្ធិមនុស្ស

១- ទទួលស្គាល់អំពីសារៈសំខាន់នៃការអប់រំ និងការហ្វឹកហ្វឺនសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា សរសើរដល់កិច្ចខិតខំរបស់រដ្ឋាភិបាលកម្ពុជា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងសង្គមស៊ីវិលក្នុងវិស័យនេះ លើកទឹកចិត្តសូមឱ្យពង្រឹង និងផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយបន្ថែមទៀតនូវកម្មវិធីទាំងនេះ និងសុំឱ្យ សហគមន៍អន្តរជាតិបន្តជួយដល់កិច្ចខិតខំទាំងនេះ ។

---

[៥] សេចក្តីសំរេចចិត្តលេខ 34/180 ឧបសម្ព័ន្ធ

២- សរសើរដល់តួនាទីជាអាយុជីវិត និងដ៏មានតម្លៃ របស់អង្គការក្រៅរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា ក្នុងនេះមានខាងវិស័យអភិវឌ្ឍន៍សង្គមស៊ីវិល និងជំរុញដល់រដ្ឋាភិបាលកម្ពុជាសូមឱ្យធានាការការពារអង្គការសិទ្ធិមនុស្សទាំងនោះ និងសមាជិករបស់គេ និងសូមឱ្យបន្តធ្វើការដោយជិតស្និទ្ធ និងដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងកិច្ចខិតខំដើម្បីពង្រឹង និងអនុវត្តន៍តាមសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ជាពិសេសក្នុងការនាំឆ្ពោះទៅការបោះឆ្នោតឃុំ/សង្កាត់ខាងមុខនេះ ។

៣- កត់សំគាល់ដោយយកចិត្តទុកដាក់ សកម្មភាពថាត់ឡើងដោយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជារបស់រដ្ឋាភិបាល គណៈកម្មការសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹងរបស់រដ្ឋសភា និងគណៈកម្មការសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹងរបស់ព្រឹទ្ធសភា គូសបញ្ជាក់អំពីសារៈសំខាន់នៃការជំរុញការទុកចិត្តបន្ថែមទៀតទៅលើស្ថាប័នទាំងនេះ និងបង្កើនសកម្មភាពរបស់ពួកគេ ហើយសូមស្នើដល់សហគមន៍អន្តរជាតិឱ្យពង្រីកជំនួយបច្ចេកទេសរបស់ខ្លួនដើម្បីទិសដៅនេះ ។

៤- លើកទឹកចិត្តរដ្ឋាភិបាលកម្ពុជា ចំពោះកិច្ចខិតខំរបស់ខ្លួនដើម្បីបង្កើតយន្តការជាតិឯករាជ្យមួយ សំរាប់ការលើកតម្កើង និងការការពារសិទ្ធិមនុស្ស ដែលត្រូវឈរលើគោលការណ៍ទាក់ទិននឹងឋានៈរបស់ស្ថាប័នជាតិនានា សំរាប់ការលើកតម្កើង និងការការពារសិទ្ធិមនុស្ស ដែលត្រូវបានស្គាល់ថា គោលការណ៍ទីក្រុងប៉ារីស៍[១០] ធ្វើការងារដោយសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយសង្គមស៊ីវិល និងសុំការិយាល័យឧត្តមស្នងការបន្តផ្តល់យោបល់ និងជំនួយបច្ចេកទេសដល់កិច្ចខិតខំទាំងនេះ ។

៥- សុំរដ្ឋាភិបាលកម្ពុជា ធ្វើតាមអនុសាសន៍របស់អង្គការសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ស្តីពីរបាយការណ៍នានាដែលបានដាក់ជូនដោយរដ្ឋាភិបាល អំពាវនាវដល់រដ្ឋាភិបាល សូមឱ្យបំពេញកាតព្វកិច្ចធ្វើរបាយការណ៍របស់ខ្លួនចំពោះឯកសារសិទ្ធិមនុស្សអន្តរជាតិទាំងអស់ ដែលប្រទេសកម្ពុជាបានចូលជាភាគី និងសុំការិយាល័យឧត្តមស្នងការប្រចាំកម្ពុជា បន្តផ្តល់ជំនួយចំពោះការណ៍នេះ ។

## VII- បញ្ហាមីន និងអាវុធធុនស្រាល

១- សំដែងសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង ចំពោះបម្រើយដ៏រង្គំរង្គាល និងបម្រើយអស្ថេរភាពនៃគ្រាប់មីនប្រឆាំងមនុស្សនៅក្នុងសង្គមកម្ពុជា ស្វាគមន៍ការរីកចំរើនធ្វើឡើងដោយរដ្ឋាភិបាលក្នុងការដោះមីនទាំងនេះ និងចំពោះកម្មវិធី

---

[១០] សូមមើលសេចក្តីសម្រេចលេខ 48/134 ឧបសម្ព័ន្ធ

ជំនួយដល់ជនរងគ្រោះ និងការយល់ដឹងអំពីមីន លើកទឹកចិត្តរដ្ឋាភិបាលសូមបន្តកិច្ចខិតខំរបស់ខ្លួន ក្នុងបញ្ហានេះ និងសរសើរដល់ប្រទេសផ្តល់ជំនួយ និងតួអង្គដទៃទៀតនៃសហគមន៍អន្តរជាតិ ចំពោះការរួមចំណែក និងជំនួយរបស់ពួកគេ ក្នុងការសកម្មភាពមីន ។

២- សំដែងសេចក្តីព្រួយបារម្ភចំពោះចំនួនអាវុធធុនស្រាលដ៏ច្រើន ដែលនៅតែស្ថិតមាននៅក្នុងសង្គម សរសើរដល់ការរីកចំរើនធ្វើឡើងដោយរដ្ឋាភិបាលក្នុងបញ្ហានេះ និងកិច្ចសហប្រតិបត្តិការរបស់សហគមន៍អន្តរជាតិក្នុងការរកផ្លូវដោះស្រាយបញ្ហានៃអាវុធធុនស្រាលនេះ និងលើកទឹកចិត្តរដ្ឋាភិបាលសូមសហប្រតិបត្តិការជាមួយកិច្ចខិតខំនៅក្នុងតំបន់ និងអន្តរជាតិ ដើម្បីកាត់បន្ថយចំនួនអាវុធធុនស្រាលខុសច្បាប់ រួមមានការអនុវត្តន៍កម្មវិធីដែលមានស្រាប់ផង ។

VIII- សេចក្តីសន្និដ្ឋាន

១- ស្នើសុំលោកអគ្គលេខាធិការរាយការណ៍ជូនមហាសន្និបាត នៅក្នុងសម័យប្រជុំលើកទី ៥៧ របស់ខ្លួន ស្តីពីតួនាទី និងការសំរេចបានរបស់ការិយាល័យឧត្តមស្នងការ ក្នុងការជួយរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកតម្កើង និងការការពារសិទ្ធិមនុស្ស និងស្តីពីអនុសាសន៍ធ្វើឡើងដោយលោកតំណាងពិសេសពីបញ្ហានានានៅក្នុងអាណត្តិរបស់លោក ។

២- សំរេចបន្តការយកចិត្តទុកដាក់របស់ខ្លួន ស្តីពីស្ថានភាពមនុស្សនៅកម្ពុជា នៅក្នុងសម័យប្រជុំលើកទី ៥៧ របស់ខ្លួន ក្នុងរបៀបវារៈដែលមានចំណងជើងថា "បញ្ហាសិទ្ធិមនុស្ស" ។

សម័យប្រជុំពេញអង្គលើកទី ៨៨
ថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០១

<u>ការបកប្រែសំរួលពីអត្ថបទដើមជាភាសាអង់គ្លេស</u>